# ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម

## Khmer Kampuchea Krom Women Organization Bulletin

*ចេញផ្សាយប្រចាំអឌ្ឍមាស ឆ្នាំទី២ លេខ៣១ ពីថ្ងៃទី០១-១៥ ខែវិច្ឆិកា ឆ្នាំ២០០៩*


# ខ្មែរកម្ពុជាក្រោម ប្រារព្ធខួបលើកទី ៣៣ នៃទិវាចលនាតស៊ូទាមទារសិទ្ធិសេរីភាព

នៅថ្ងៃច័ន្ទ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅវត្តសាមគ្គីរង្សី ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ បានប្រារព្ធខួបលើកទី៣៣ នៃទិវាចលនាតស៊ូទាមទារសិទ្ធិសេរីភាព នៅដែនដីកម្ពុជាក្រោម (១៦-១១-១៩៧៦ ១៦-១១-២០០៩) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ព្រះឧបជ្ឈាយ៍មហា **យៀង សិន** ព្រះប្រធានសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម ដោយមានការចូលរួមជាគណៈអធិបតីពីសំណាក់ **ឯកឧត្តម យន្ត ថារ៉ូ** សមាជិករដ្ឋសភា **ឯកឧត្តម ថាច់ សេដ្ឋា** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ **ឯកឧត្តម វ៉ាន់ ស៊ីវឿន** សមាជិកព្រឹទ្ធសភា **ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ** សមាជិករដ្ឋសភា និងបណ្ដាអង្គការ-សមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជា ហើយមានអង្គការ និងសារពត៌មានជាតិ-អន្តរជាតិជាច្រើនរូប ព្រមទាំងព្រះសង្ឃ និងគ្រហស្ថប្រមាណ៥០០រូប បានចូលរួមធ្វើឱ្យពិធីនោះមានសភាពឱឡារិកអធិកអធម។

បន្ទាប់ពីគោរពភ្លេងជាតិ គោរពវិញ្ញាណក្ខន្ធយុទ្ធជន-យុទ្ធនារី ដែលបានស្លាប់ដោយយុវនារីខ្មែរកម្ពុជាក្រោម និងអុជធូបគោរពវិញ្ញាណក្ខន្ធ ព្រមទាំងព្រះសង្ឃជយន្តោជូនអង្គពិធីរួចមក។ **ឯកឧត្តម យន្ត ថារ៉ូ** សមាជិករដ្ឋសភាបានសំដែងនូវបុព្វហេតុដែលនាំឱ្យកើតកម្មវិធី និងប្រកាសបើកកម្មវិធី។ **លោក គឹម ប៊ុកកែវ** មានសុន្ទរកថាតំណាងឱ្យជនរងគ្រោះ **លោក សឺន យឿង** នាយកប្រតិបត្តិសមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ និង**ឯកឧត្តម ថាច់ សេដ្ឋា** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ មានសុន្ទរកថានៅក្នុងពិធីដ៏ឱឡារិកអធិកអធមនោះ។ ខ្លឹមសារនៃសុន្ទរកថាទាំងអស់ គឺផ្ដោតទៅលើ



*រូបថតអនុស្សាវរីយ៍នៅកន្លែងប្រារព្ធពិធី*



*ព្រះសង្ឃជយន្តោប្រសិទ្ធិពរជូនអង្គពិធី*


**អាសយដ្ឋាន: ផ្ទះលេខ១៩ ផ្លូវ២៩៤ ក្រុម៦៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ**

**ទូរស័ព្ទ: ០១១ ៧១ ២៣ ២៥ / ០១១ ៦៣ ៦០ ១២**

E-mail: kkkwo@yahoo.com


**ចែកជូនដោយឥតគិតថ្លៃ**

ទង្វើរបស់រដ្ឋាភិបាលវៀតណាមដ៏អមនុស្សធម៌ មកលើបងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម កាលពីអតីតកាលរហូតមកដល់បច្ចុប្បន្នកាលនេះ ដោយហេតុថាព្រឹត្តិការណ៍ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ បងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម មានការឈឺចាប់យ៉ាងខ្លាំង នូវទង្វើទាំងឡាយរបស់អាជ្ញាធរវៀតណាម ដូចជាការបែងចែករបប និងការបែងចែកតួនាទីនៅក្នុងជួររដ្ឋាភិបាល នៃថ្នាក់មូលដ្ឋាន មានការរើសអើងយ៉ាងខ្លាំង និងការគោរពប្រពៃណី ទំនៀមទំលាប់ ជំនឿសាសនាត្រូវបានរឹតបណ្តឹង ព្រមទាំងមានការបិទសិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងរជាទីបំផុត នៃការសិក្សារៀនសូត្រ ពិសេសសហព័ន្ធសិស្ស គឺជាសិស្សឈានមុខរាប់ពាន់នាក់ត្រូវបានបិទទាំងស្រុង។ ដូច្នេះការទាមទារ របស់បងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម គឺជារឿងត្រឹមត្រូវ មិនគួរណារដ្ឋាភិបាលវៀតណាមប្រើអាវុធស្វ័យប្រវត្តិទំនើបៗ បាញ់ប្រហារមកលើប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមបែបនេះឡើយ នោះគឺជាទង្វើអមនុស្សធម៌យ៉ាងពិតប្រាកដ។

ចំពោះ**ឯកឧត្តម វ៉ាន់ ស៊ីវឿន** តំណាងឱ្យគណបក្សសមរង្ស៊ី **និងឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ** តំណាងឱ្យគណបក្សសិទ្ធិមនុស្ស មានមតិគាំទ្រខ្មែរកម្ពុជាក្រោម១០០ភាគរយ ហើយសន្យាថាពេលណាគណបក្សធំទាស់កាន់អំណាច និងជួយជ្រោមជ្រែងជំរុញឱ្យខ្មែរកម្ពុជាក្រោម មានសិទ្ធិសេរីភាពពេញបរិបូរណ៍ទាំងនៅកម្ពុជា ក៏ដូចជានៅឯដែនដីកម្ពុជាក្រោម ហើយសូមយកគំរូតាមបងប្អូនខ្មែរកម្ពុជាក្រោម ដែលគិតគូរប្រារព្ធពិធីដឹងគុណ នូវវីរភាពនៃយុទ្ធជន-យុទ្ធនារីដែលមានពិធីដ៏ឱឡារិកអធិកអធមនាពេលនេះ។ ដោយឡែក**ព្រះឧបជ្ឈាយ៍ មហា យឿង សិន** មានសង្ឃដីការថា ព្រះអង្គគឺជាពូជអ្នកស្លាប់ បើមិនស្លាប់ឥឡូវ ដល់ចាស់ក៏ស្លាប់ដែរ។ ម្ល៉ោះហើយព្រះអង្គមិនដែលខ្លាចយូនទេ ទោះបីបិតនៅក្នុងកាលៈទេសៈណាក៏ដោយ ហើយការប្រារព្ធពិធីកាន់ទុក្ខខួបលើកទី៣៣ នៃទិវាចលនាតស៊ូទាមទារសិទ្ធិសេរីភាពរបស់យុទ្ធជន-យុទ្ធនារីខ្មែរកម្ពុជាក្រោមនាពេលនេះ គឺកើតឡើងដោយអង្គការ-សមាគមខ្មែរកម្ពុជាក្រោមទាំងអស់នៅកម្ពុជា ដូចមាននៅក្នុងកម្មវិធីបុណ្យស្រាប់។ ដូច្នេះអាត្មាមានទឹកចិត្តសប្បាយរីករាយដោយ ឃើញបងប្អូនខ្មែរកម្ពុជាក្រោម ចេះស្រឡាញ់គ្នា សាមគ្គីគ្នា ពុំគិតពីការនៀយហត់អ្វីឡើយ នេះជាមោទនភាពមួយសំរាប់ជាតិយើង។

**លោកតាអាចារ្យ ថាច់ គង់** បានធ្វើពិធីនមស្សការ សមាទានសីល ដារបង្សុកូល ឧទ្ទិសកុសលជូនដល់យុទ្ធជនយុទ្ធនារីដែលបានពលីជីវិត ក្នុងព្រឹត្តិការណ៍ ១៦ វិច្ឆិកា ១៩៧៦ ឱ្យលោកបានទទួលនូវបុណ្យកុសល ទៅកើតនាឋានបរមសុខគ្រប់ៗរូបកុំបីអាក់ខានឡើយ ហើយជាចុងក្រោយបានវេរចង្ហាន់ ប្រគេនព្រះសង្ឃចំនួន១០៣អង្គ ក្នុងវត្តសាមគ្គីរង្សីនោះតែម្តង។ សូមបញ្ជាក់ផងដែរថា នៅក្នុងពេលកំពុង ដំណើរការនៃពិធីមានបងប្អូនប្រជាពលរដ្ឋដែលបានចូលរួម នាំគ្នាអុជធូបគោរពវិញ្ញាណក្ខន្ធជាបន្តបន្ទាប់នៅ កន្លែងចេតិយដែលមានកំរងផ្កា និងពាក្យស្លោក ដែលរៀបចំនៅក្នុងពិធីនោះ ធ្វើឱ្យយើងមានអារម្មណ៍ក្តុកក្តួលយ៉ាងក្រៃលែង គួបផ្សំជាមួយនឹងការសូត្របទគោរពវិញ្ញាណក្ខន្ធ ដែលមានខ្លឹមសារថា *ចិត្តអើយសែននឹកដល់ជនដែលឃ្លាត ព្រោះប្រយោជន៍ជាតិពូជពង្សខេមរា ខំប្រឹងតស៊ូដល់ប្តូរជីវា ការពារនូវជាតិសាសនាឱ្យបានស្ថិតស្ថេរស្ថាពរ* និងមួយឃ្លាចុងក្រោយ *ពេលនឹកដល់ជនដែលឃ្លាតកាលណា ស្រក់ទឹកនេត្រាដែល ថ្លាដូចពេជ្រ យើងខ្ញុំនឹកណាស់គ្មានពេលណាភ្លេច ពេលព្រះសូរិយារៀបលិច នឹកដល់ព្រលឹងឃ្លាតទៅ*។ ពិសេសទៅទៀតនោះ គឺពិធីករកញ្ញា សើ វុឌ្ឍី និងអ្នកស្រី ជោត ធីតា ដែលជាស្ត្រីខ្មែរកម្ពុជាក្រោម បានអត្ថាធិប្បាយដ៏អន្ទងអន្ទោចនៅវីរភាពនៃសេចក្តីអង់អាចក្លាហានរបស់យុទ្ធជន-យុទ្ធនារីខ្មែរកម្ពុជាក្រោម ។

# កិច្ចប្រជុំប្រចាំឆ្នាំ២០០៩ នៃអង្គការ-សមាគមខ្មែរកម្ពុជាក្រោម នៅកម្ពុជា

នៅថ្ងៃច័ន្ទ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅទីស្នាក់ការសមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (KKKHRDA) ឋិតនៅក្នុងសហគមន៍បុរីព្រៃនគរ នាភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ បានបើកអង្គប្រជុំ ដែលមានការចូលរួមពីបណ្ដាអង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងអង្គការសិទ្ធិមនុស្សអន្តរជាតិ (UNCHR) ដើម្បីស្វែងយល់ និងប្រមូលពត៌មាន ស្ដីពីការរំលោភសិទ្ធិមនុស្សរបស់បងប្អូនខ្មែរកម្ពុជាក្រោម។

បន្ទាប់ពីអង្គការ សមាគមខ្មែរកម្ពុជាក្រោមនីមួយៗបានរាយការណ៍ អំពីសកម្មភាពរបស់ខ្លួនចប់សព្វគ្រប់ហើយនោះ អង្គប្រជុំបានធ្វើការជជែកវែកញែក អំពីការខ្វះខាតនៃការជួយដល់បងប្អូនខ្មែរកម្ពុជាក្រោម រយៈពេលកន្លងមក ហើយក៏បានធ្វើការវាយតំលៃថាការជួបជុំគ្នានាថ្ងៃនេះ គឺជាការងារមួយដ៏ល្អប្រសើរ ដែលយើងបានចែករំលែកពត៌មានគ្នា និងបានចែករំលែកបទពិសោធន៍ទៅវិញទៅមក ព្រមទាំងបានស្វែងយល់បន្ថែមមួយកំរិតទៀត អំពីការរស់នៅរបស់បងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម ពិសេសការសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលរស់នៅតាមបណ្ដាខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានច្រើន ទើបយើងបានទទួលពត៌មានជាបន្តបន្ទាប់ អំពីការរស់នៅរបស់ពួកគាត់។ តាមការសំណូមពររបស់អង្គប្រជុំ សូមឱ្យមានការជួបជុំគ្នាបែបនេះឱ្យបានច្រើនថែមទៀត ចាប់ពីនេះតទៅ ដើម្បីជាភាពកក់ក្ដៅដល់បងប្អូនប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ងាយស្រួលក្នុងការស្វែងរកអង្គការ-សមាគមខ្មែរកម្ពុជាក្រោម ឱ្យជួយធ្វើអន្តរាគមន៍។



*ទិដ្ឋភាពរួមនៃអង្គប្រជុំ របស់អង្គការ-សមាគមខ្មែរកម្ពុជាក្រោម នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩*

# ខ្មែរកម្ពុជាក្រោម ឈឺចិត្ត ខ្លោចផ្សា

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅទីរួមខេត្តឃ្លាំង នៃទឹកដីកម្ពុជាក្រោម (ភូសាំងស៊ីន) មានការរៀបចំមហាសន្និបាតអ្នកតំណាងសិល្បៈរបស់ជនជាតិដើមភាគតិច ក្រោមការចាត់ចែងទូទៅរបស់អាជ្ញាធរមូលដ្ឋាន និងមានការចូលរួមពីបណ្ដាសិល្បៈករ សិល្បៈការិនីខ្មែរ ហើយមានព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមប្រមាណជាជាង៤០០រូប បានចូលរួមទស្សនាផងដែរ។ ប៉ុន្តែគួរឱ្យសោកស្ដាយយ៉ាងក្រៃលែង ដោយ*លោក ឡេង វាំងគីន* អនុប្រធានគណៈកម្មការជនជាតិខេត្ត បានឡើងថ្លែងថា វប្បធម៌ ប្រពៃណីរបស់ជនជាតិខ្មែរភាគតិច ដែលអាចថែរក្សាបានរហូតមកទល់នឹងពេលនេះ គឺដោយសារតែមានការយកចិត្តទុកដាក់ពីរដ្ឋ។ ត្រង់ចំណុចនេះសូមបញ្ជាក់ដែរថា សំដីរបស់ *លោក ឡេ វាំងគីន* គឺជាការមិនពិតពីព្រោះជនជាតិខ្មែរ នៅក្នុងខេត្តឃ្លាំងទាំងមូល ក៏ដូចជានៅក្នុងទឹកដីកម្ពុជាក្រោមទាំងអស់ គឺជាជនជាតិដើមនៃទឹកដីកម្ពុជាក្រោម មិនមែនជាជនជាតិភាគតិច ដូចដែលលោក ឡេ វាំងគីន បាននិយាយដោយបំភ្លើសនោះទេ។ម្យ៉ាងទៀត អ្វីដែលរដ្ឋអំណាចវៀតណាម បាននឹងកំពុងតែធ្វើនេះគឺមានការលុបបំបាត់ចោលទាំងស្រុង នូវវប្បធម៌របស់ជនជាតិដើមនៅទីនោះ ព្រោះថាមហាសន្និបាតតំណាងសិល្បៈរបស់ជនជាតិដើមនេះ ធ្វើឡើងក្នុងរូបភាពជាខ្មែរ ក៏ប៉ុន្តែរដ្ឋអំណាចនៅទីនោះបានប្រែក្លាយពីរូបភាពខ្មែរទៅជាវៀតណាមទៅវិញ ដូចជាការបំរើកម្មវិធី និងការរៀបចំនានានៅក្នុងពិធីនោះ សុទ្ធតែប្រើប្រាស់អក្សរ និងភាសាវៀតណាមទាំងអស់នៅលើវេទិកា ដែលពីមុនមកពុំធ្លាប់មាន មានន័យថាកម្មវិធី និងនាទីរបស់ខ្មែរ កាលពីមុន គឺទុកឱ្យខ្មែរចាត់ចែង នឹងរៀបចំ ទាំងការសំដែង ទាំងពិធីករ និងបដា គឺត្រូវតែជាអក្សរខ្មែរទាំងអស់។ ទង្វើទាំងអស់នេះ ហើយធ្វើឱ្យខ្មែរទាំងអ្នកសំដែង និង អ្នកចូលរួមមានការតូចចិត្ត និងឈឺចាប់ជាទីបំផុតដែលរកអ្វីមកប្រៀបផ្ទឹមពុំបាន គឺនិយាយមិនចេញ។ តាមប្រសាសន៍របស់សិល្បៈករសំដែងមួយរូបក្នុងចំណោមសិល្បៈករជាច្រើន បាននិយាយថា ខ្ញុំបានចូលរួមសំដែងពិតមែន ប៉ុន្តែខ្ញុំមានអារម្មណ៍សំដែងទេ ពីព្រោះលើកនេះ គេ(វៀតណាម)បំបិទសិទ្ធិខ្មែរយើងអស់ហើយ។ ចំពោះព្រះតេជគុណមួយព្រះអង្គ ក៏សូមមិនបញ្ចេញឈ្មោះព្រោះភ័យខ្លាចពីសុវត្ថិភាព បើអញ្ចឹងទៅមិនយូរទេ វប្បធម៌ខ្មែរយើងមុខជាបាត់បង់មិនខាន ព្រោះអីកម្មវិធីខ្មែរសំដែងសោះ តែបែរជាយួនគេគ្រប់គ្រងទៅវិញ អាត្មាមិនដឹងថានិយាយម៉េចដែរ បើនិយាយទៅវាមិនបាន ម្ល៉ោះហើយមានការឈឺចាប់ ខ្លោចផ្សាយ៉ាងខ្លាំង ។



សិល្បៈករ,សិល្បៈការិនីខ្មែរនៅឯដែនដីកម្ពុជាក្រោម

រាល់ការជួយឧបត្ថម្ភបោះពុម្ពព្រឹត្តិបត្រ មេត្តាទាក់ទងលេខទូរស័ព្ទនៅទំព័រខាងលើ សូមអរគុណ